មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

**កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក**

ខែមេសា ឆ្នាំ២០១៤

# ប្រទេសកម្ពុជា៖ សេរីភាពខាងការជួបប្រជុំ កំពុងតែត្រូវបាន “ព្យួរ”


## ខ្លឹមសារសង្ខេប

កំណត់ត្រាសង្ខេបនេះ ផ្តោតសំខាន់លើសេរីភាពខាងការជួបប្រជុំនៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) និងបម្រាមពុំស្របច្បាប់នាពេលបច្ចុប្បន្នទៅលើការជួបប្រជុំទាំងអស់ ដែលក្រសួងមហាផ្ទៃរបស់រាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) បានប្រកាស នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤។ បើទោះជាមានការលើកសំណើនៅពេលថ្មីៗនេះថា រដ្ឋាភិបាលបានដកបម្រាមនោះ ដូចបានចេញផ្សាយតាមបណ្តាញព័ត៌មាននានានោះក្តី ក៏បម្រាមនេះ នៅតែមានការអនុវត្តន៍យ៉ាងតឹងរ៉ឹង។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) បានប្រមូលចងក្រងករណីជាច្រើន[1] ដែលពាក់ព័ន្ធនឹងសិទ្ធិសេរីភាពខាងការជួបប្រជុំត្រូវរដ្ឋាភិបាលបានរឹតត្បិតចាប់តាំងពីមានការប្រកាសបម្រាមជួបប្រជុំដំបូង។ ដោយសារការវិវឌ្ឍន៍ទាំងនោះ កំណត់ត្រាសង្ខេបនេះ ផ្តល់នូវទិដ្ឋភាពទូទៅ និងការវិភាគជុំវិញបច្ចុប្បន្នភាពនៃសេរីភាពខាងការជួបប្រជុំនៅកម្ពុជា។

បម្រាមលើការជួបប្រជុំ កំពុងត្រូវបានអនុវត្តនៅក្នុងបរិបទនៃការជាប់គាំងនយោបាយដែលកំពុងតែបន្តចាប់តាំងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅខែកក្កដា ឆ្នាំ២០១៣ គណបក្សសង្គ្រោះជាតិ (“គ.ស.ជ”) បានពហិកាចូលរដ្ឋសភា ដោយទាញហេតុផលថា ការបោះឆ្នោតមានភាពមិនប្រក្រតីច្រើន ហើយបានធ្វើមហាបាតុកម្មជាប្រចាំ។ នៅដើមខែមករា ឆ្នាំ២០១៤ ឃើញមានការបង្ក្រាបយ៉ាងហិង្សាពីសំណាក់កងកម្លាំងសន្តិសុខលើអ្នកតវ៉ារបស់ គ.ស.ជ និងកម្មកររោងចក្រ ដែលបាតុកម្មរបស់កម្មកររោងចក្រធ្វើឡើងដើម្បីទាមទារឲ្យមានការតម្លើងប្រាក់ឈ្នួលអប្បបរមា។ ការបង្ក្រាបទាំងនោះ បណ្តាលឲ្យមានមនុស្សយ៉ាងហោចណាស់ចំនួន៤នាក់ស្លាប់ រាប់សិបនាក់ទៀតរងរបួស និងមានការចាប់ខ្លួនមនុស្សចំនួន២៣នាក់ ដែលក្នុងចំណោមនោះ មនុស្ស២១នាក់កំពុងតែជាប់ឃុំ។

ផ្នែកដំបូងនៃកំណត់ត្រាសង្ខេបនេះ បង្ហាញថា បម្រាមនៅពេលបច្ចុប្បន្ននេះលើការជួបប្រជុំ គឺពុំស្របតាមច្បាប់កម្ពុជា។ ផ្នែកទីពីរ ត្រួតពិនិត្យទៅលើការអនុវត្តន៍បម្រាម ការប្រើកងកម្លាំងសន្តិសុខឯកជនដែលពុំមានការហ្វឹកហ្វឺន ការហាមប្រាមលើការតវ៉ា ការបំភិតបំភ័យ និងអំពើហិង្សា ព្រមទាំងការឃុំខ្លួនទៅលើអ្នកការពារសិទ្ធិមនុស្ស និងអ្នកតវ៉ានានាជាបណ្តោះអាសន្ន។ ផ្នែកបញ្ចប់ នឹងធ្វើសេចក្តីសន្និដ្ឋាន ព្រមទាំងលើកឡើងនូវអនុសាសន៍នានា ដែលក្នុងចំណោមអនុសាសន៍ទាំងនោះ គឺមានសំណើសំខាន់ៗមួយចំនួនខាងក្រោមនេះ ដើម្បីដាក់ជូនទៅរដ្ឋាភិបាល ៖


---

[1] ព័ត៌មានត្រូវបានប្រមូលតាមរយៈជនរងគ្រោះ និងតាមរយៈការតាមដានលើបណ្តាញព័ត៌មានទាំងជាតិ និងអន្តរជាតិ។

- និរាករណ៍ជាបន្ទាន់ និងជាផ្លូវការនូវបម្រាមលើការជួបប្រជុំគ្រប់យ៉ាង ការហែក្បួន និងការធ្វើបាតុកម្មនានានៅកម្ពុជា ។
- បញ្ឈប់ការឃុំខ្លួនជាបណ្តោះអាសន្នដោយខុសច្បាប់លើអ្នកតវ៉ាដោយសន្តិវិធី និងត្រូវដោះលែងអ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ឃុំ ដោយសារចូលរួមនៅក្នុងសកម្មភាពតវ៉ាដោយសន្តិវិធី។
- បញ្ឈប់នូវការអនុវត្តន៍ការបង្ខិតបង្ខំចំពោះអ្នកការពារសិទ្ធិមនុស្សនិងពលរដ្ឋដែលគ្រាន់តែអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិនិងការជួបប្រជុំជាមូលដ្ឋានរបស់ខ្លួន ឲ្យចុះហត្ថលេខាលើកិច្ចសន្យាមានលក្ខណៈរឹតត្បិតលើសិទ្ធិរបស់ពួកគាត់ ដើម្បីជាថ្នូរនឹងការដោះលែង ឬរួចផុតពីការចោទប្រកាន់នានា។
- ធានាឲ្យមន្ត្រីសន្តិសុខទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ហើយបញ្ឈប់ការជួលកងកម្លាំងសន្តិសុខឯកជន និង,
- ធានាថា ការរឹតត្បិតលើសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីនឹងត្រូវបានហាមប្រាមនៅពេលអនាគត។

កំណត់ត្រាសង្ខេបនេះ តាក់តែងឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

## បម្រាមលើការជួបប្រជុំរំលោភលើច្បាប់ជាតិកម្ពុជា

នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤ បន្ទាប់ពីការបង្ក្រាបយ៉ាងហិង្សាទៅលើអ្នកតវ៉ា ក្រសួងមហាផ្ទៃបានចេញសេចក្តីថ្លែងការណ៍មួយដោយចែងថា នឹងមានការហាមប្រាមលើបាតុកម្ម ការជួបប្រជុំ ឬការហែក្បួនបន្តទៀតរហូតដល់ "*សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខត្រូវបានស្តារឡើងវិញ*"។ សាលាក្រុងភ្នំពេញ ក៏បានផ្ញើលិខិតមួយច្បាប់ជូនចំពោះលោក សម រង្ស៊ី ប្រធាន គ.ស.ជ ដោយច្រានចោលការជូនដំណឹងស្តីពីការតវ៉ារបស់ គ.ស.ជ នៅថ្ងៃខាងមុខ ហើយបានលើកឡើងថា គ.ស.ជ នឹងមិនត្រូវបានអនុញ្ញាតឲ្យហែក្បួន ឬបាតុកម្មនានា រហូតដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈត្រូវបានធានា។[2] យោងតាមឧត្តមសេនីត្រីយ ខេង ទីតូ អ្នកនាំពាក្យកងរាជអាវុធហត្ថបញ្ជាក់ថា "*សណ្តាប់ធ្នាប់សាធារណៈនិងសន្តិសុខត្រូវបានស្តារឡើងវិញ*"មានន័យថាបម្រាមនឹងដកនៅពេលគ.ស.ជ ចូលអង្គុយនៅក្នុងរដ្ឋសភា។[3]

បន្ថែមពីនេះ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤ សាលាខេត្តកំពង់ឆ្នាំង បានចេញសារាចរមួយស្តីពីការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ សហជីព អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា។ សារាចរនេះ ណែនាំថា ដើម្បីរៀបចំមហាបាតុកម្មមួយទៅបាន អ្នករៀបចំត្រូវសុំការអនុញ្ញាតពីអាជ្ញាធរខេត្តក្នុងរយៈពេល ៧ ថ្ងៃជាមុនសិន ដើម្បីឲ្យអាជ្ញាធរខេត្តកំណត់ថាតើបាតុកម្មនោះ "ស្របច្បាប់" ដែរឬយ៉ាងណា។ ប្រសិនបើពុំមានសំណើសុំការអនុញ្ញាត

---

[2] មិច ដារា និងផេតធើ ហ្សូបើ "បម្រាមលើការតវ៉ានឹងបន្តរហូតដល់គណបក្សប្រឆាំងចូលសភា" កាសែត *ខេមបូឌា ដេលី* (ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ អាចរកបានតាម៖http://bit.ly/1jzlVGr> ។

[3] មានប្រភពដូចខាងលើ។

ទេនោះ "*អាជ្ញាធរមានសមត្ថកិច្ច នឹងចាត់វិធានការដាក់លាក់ប្រឆាំងនឹងការប្រមូលផ្តុំ ហើយអ្នករៀបចំបាតុកម្មនោះ នឹងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន*"។[4] នេះគឺជាការរំលោភដោយផ្ទាល់ទៅលើច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩ ដែលតម្រូវឲ្យមានការជូនដំណឹងក្នុងរយៈពេល៥ថ្ងៃ នៃថ្ងៃការងារ។

នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១៤ មានការលើកឡើងថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បម្រុងនឹងដកបម្រាមលើការជួបប្រជុំក្នុងអំឡុងពេលសុន្ទរកថាមួយនៅក្នុងខេត្តព្រះសីហនុ ដោយលោកនាយករដ្ឋមន្ត្រីបានថ្លែងថា"*នៅពេលនេះ ខ្ញុំមិនបានស្នើឲ្យធ្វើបាតុកម្មទេ តែក៏មិនរារាំងដល់បាតុកម្មដែរ*" ដោយលោកបានបន្ថែមថា លោក "*ត្រូវតែជានាសន្តិភាពសម្រាប់ប្រជាពលរដ្ឋ ក៏ដូចជា ធានាដល់សិទ្ធិជួបប្រជុំរបស់ប្រជាពលរដ្ឋគ្រប់រូប*"។[5] សេចក្តីប្រកាសនេះបាននាំទៅរកការភាន់ច្រឡំថាតើបម្រាមនោះត្រូវបានដកឬយ៉ាងណា នេះរួមទាំងក្នុងចំណោមមន្ត្រីរដ្ឋាភិបាលនោះផង។ តែយ៉ាងណាក្តី ចាប់តាំងពីនោះមក ការតវ៉ានានាត្រូវបានហាមប្រាម ដែលនេះបង្ហាញថា បម្រាមនោះនៅតែត្រូវអនុវត្តយ៉ាងតឹងរ៉ឹង។

សិទ្ធិសេរីភាពខាងការជួបប្រជុំ ត្រូវបានលើកកម្ពស់ និងការពារក្រោមច្បាប់កម្ពុជា។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា "*ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ*"។[6] មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញ ក៏បានចែងផងដែរថា ប្រជាពលរដ្ឋទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ។[7]

បន្ថែមលើនេះ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា ប្រទេសកម្ពុជាទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (ស.ស.ស.ម) និងកតិកាសញ្ញា និងអនុសញ្ញានានាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស[8] តាមរយៈការដាក់បញ្ចូល ស.ស.ស.ម និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ចូលទៅក្នុងច្បាប់ជាតិ។[9] សិទ្ធិសេរីភាពខាងការជួបប្រជុំមានចែងទាំងនៅក្នុង ស.ស.ស.ម និង ក.អ.ស.ព.ន។ មាត្រា ២០ នៃ

---

[4] ក្រសួងមហាផ្ទៃ សារាចរស្តីពីមហាបាតុកម្មនៅខេត្តកំពង់ឆ្នាំង ចំពោះគណបក្សនយោបាយទាំងអស់ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងសមាគមដទៃទៀតមានមូលដ្ឋាននៅខេត្តកំពង់ឆ្នាំង (ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤)។

[5] ខី សុវុទ្ធី និង ខូលីន មីយ៉ាន់ "លោក ហ៊ុន សែន ដកបម្រាមលើការតវ៉ា ដោយធ្វើការប្រមានពីបាតុកម្មបកពីអ្នកគាំទ្ររបស់គណបក្សប្រជាជន" កាសែត *ខេមបូឌា ដេលី* (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1heCg46។

[6] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។ មាត្រា ៤១ http://bit.ly/19Ey1Ms>។

[7] មានប្រភពដូចខាងលើ មាត្រា៣៥។

[8] មានប្រភពដូចខាងលើ មាត្រា៣១។

[9] កាតព្វកិច្ចអនុវត្តដោយផ្ទាល់លើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ត្រូវបានបញ្ជាក់បន្ថែម នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលចែងថា ចៅក្រមមានកាតព្វកិច្ចពិចារណាលើច្បាប់កម្ពុជា នៅពេលបកស្រាយច្បាប់ និងធ្វើសេចក្តីសម្រេច។

ស.ស.ស.ម ចែងថា "*មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការបង្កើតសមាគមដោយសន្តិវិធី*"។[10] សិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី ក៏ត្រូវបានធានាផងដែរក្រោមមាត្រា ២១ នៃ ក.អ.ស.ព.ន។

<u>ការរឹតត្បិតលើសិទ្ធិជួបប្រជុំដោយសន្តិវិធី ទាល់តែក្នុងករណីចាំបាច់ សមហេតុផល និងត្រឹមត្រូវតាមច្បាប់</u>

មាត្រា ២១ នៃ ក.អ.ស.ព.ន ផ្តល់ការណែនាំនូវការរឹតត្បិតលើសេរីភាពខាងការជួបប្រជុំដែលអាចទទួលយកបានដោយចែងថា "*សិទ្ធិជួបប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់។ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរឹតត្បិត ដែលកំណត់ដោយច្បាប់ប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ*" ដើម្បីធានាដល់ "*សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ*"។[11] ជាងនេះទៀត យោងតាមច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩ ចែងនៅក្នុងបុព្វបទរបស់ខ្លួនថា "*ការរឹតត្បិតណាមួយលើការធ្វើបាតុកម្ម គួរតែសមហេតុផល*"។[12]

លោក ម៉ៃណា គីអៃ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិបង្កើតសមាគម បានផ្តល់អនុសាសន៍នៅក្នុងរបាយការណ៍របស់លោកទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ ថា "*ដើម្បីធានាថា ការរឹតត្បិតណាមួយលើសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម មានចែងក្នុងច្បាប់ ចាំបាច់ក្នុងសង្គមលទ្ធិប្រជាធិបតេយ្យ និងសមស្របតាមគោលបំណងច្បាប់ ហើយមិនប៉ះពាល់ដល់គោលការណ៍លទ្ធិប្រជាធិបតេយ្យនោះ ចាំបាច់ត្រូវមានការអត់ឱន និងមានសន្តានចិត្តបើកទូលាយ។ ការរឹតត្បិតណាមួយ ត្រូវតែត្រួតពិនិត្យឡើងវិញជាបន្ទាន់ទៅលើភាពយុត្តិធម៌ ឯករាជ្យ និងមិនលម្អៀង*"។[13] ជាងនេះទៅទៀត គណកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានលើកឡើងថា "នៅពេលការរឹតត្បិតនេះធ្វើឡើង រដ្ឋត្រូវតែបង្ហាញនូវភាពចាំបាច់ និងចាត់វិធានការសមស្របអនុលោមតាមគោលបំណងច្បាប់ ដើម្បីធានាឲ្យមានការការពារជាបន្ត និងប្រកបដោយប្រសិទ្ធិភាពនូវសិទ្ធិនានាដែលមានចែងក្នុងអនុសញ្ញា"។[14] ដូច្នោះហើយ ការរឹតត្បិតលើសិទ្ធិសេរីភាពខាងការជួបប្រជុំត្រូវបានហាមប្រាមនៅក្នុងកាលៈទេសៈដ៏តូចចង្អៀតតែប៉ុណ្ណោះ ហើយការហាមប្រាមនោះ ត្រូវតែសមស្របទៅតាមគោលបំណងច្បាប់។

---

[10] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ មហាសន្និបាតរបស់ អ.ស.ប ដំណោះស្រាយលេខ ២១៧ ក (៣) (ស.ស.ស.ម) មាត្រា២០ អាចរកបានតាម៖ <http://bit.ly/1aRyxCs>។

[11] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) មាត្រា២១ អាចរកបានតាម៖http://bit.ly/1eeGc40។

[12] ក្រសួងមហាផ្ទៃ ការអនុវត្តតាម ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី (ឆ្នាំ២០០៩) អាចរកបានតាម៖http://bit.ly/190IFJx។

[13] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកផ្នែកសិទ្ធិសេរីភាពខាងការជួបប្រជុំ និងការបង្កើតសមាគម។ ម៉ាយណា គីអាយ (របាយការណ៍) (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២) អាចរកបានតាម៖ <http://bit.ly/1fd7O6A>។

[14] គណកម្មការទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស៖ វិចារណៈកថាទូទៅលេខ ៣១ (លេខ៨០) ប្រភេទនៃកាតព្វកិច្ចផ្លូវច្បាប់ទូទៅស្តីពីរដ្ឋភាគីនៃអនុសញ្ញា ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ អាចរកបានតាម៖ http://bit.ly/1lfYshS។

បម្រាមបច្ចុប្បន្ននេះ ទៅលើការធ្វើបាតុកម្ម ការហែក្បួន និងការជួបប្រជុំទាំងអស់ក្នុងទីសាធារណៈណាក៏ដោយ បង្កើតបានជាការរឹតត្បិតមួយស្របច្បាប់ទាំងស្រុង ដែលនេះជាការរឹតត្បិតហួសហេតុពេក ហើយពុំសមហេតុផល ព្រោះថាគ្មានហេតុផលត្រូវបានលើកឡើងពីកាលៈទេសៈជាក់លាក់នៃករណីនីមួយៗនោះទេ។ បម្រាមបង្ហាញពីការរឹតត្បិតហួសហេតុនេះ កើតមានឡើងចាប់តាំងពីមានការតវ៉ានានានៅតំបន់ជុំវិញទីក្រុងភ្នំពេញមកម្លេះ។

ម្យ៉ាងវិញទៀត ខណៈដែលមានបម្រាមទៅលើបាតុកម្ម ការជួបប្រជុំ ឬការហែក្បួននានា អាចត្រូវបានផ្តល់ហេតុផលសមរម្យ និងជាការចាំបាច់ដោយផ្អែកលើហេតុផលសណ្តាប់ធ្នាប់សាធារណៈ ជាពិសេស ធ្វើឡើងភ្លាមៗបន្ទាប់ពីព្រឹត្តិការណ៍ហិង្សានោះ ការអះអាងបែបនេះ នឹងបាត់បង់ទៅវិញដោយខ្លួនឯងនៅពេលវេលាកន្លងទៅ។ សម្រាប់ហេតុផលនេះ បម្រាមណាមួយទៅលើការហែក្បួន ការធ្វើបាតុកម្ម និងការជួបប្រជុំ គួរតែត្រូវកំណត់ឲ្យបានតឹងរ៉ឹងទាន់ពេលវេលា។ ផ្ទុយទៅវិញ ខណៈដែលបម្រាមបច្ចុប្បន្ននេះចែងថា ជាបម្រាមបណ្តោះអាសន្ននោះ លទ្ធភាពបញ្ចប់បម្រាមគឺជាកម្មវត្ថុចំពោះការបកស្រាយដោយអត្តនោម័តពេកទៅលើអ្វីដែលចាត់ទុកថា *"សណ្តាប់ធ្នាប់សាធារណៈត្រូវស្តារឡើងវិញនោះ"* នេះបើតាមការលើកឡើងនាពេលថ្មីៗរបស់ឧត្តមសេនីយត្រី ខេង ទីតូ។ នៅក្នុងបរិបទបច្ចុប្បន្ននេះ បម្រាមនោះគឺពិតជាពុំចាំបាច់តទៅទៀតនោះទេ នៅរយៈពេលបួនខែបន្ទាប់ពីមានការប៉ះទង្គិចដោយហិង្សាបានកើតឡើងរវាងនគរបាល និងបាតុករមក ។

ដោយសារការជាប់គាំងនយោបាយ និងការកើនឡើងនូវករណីប្រឆាំងតវ៉ានៅកម្ពុជា និងចរិតនៃបម្រាមលើការជួបប្រជុំដែលមិនមានលក្ខណៈចាំបាច់ និងពុំសមហេតុផលនោះ គោលបំណងស្របតាមច្បាប់នៃបម្រាមនេះមានលក្ខ–ណៈគួរឲ្យសង្ស័យណាស់។ ស្ថានភាពបច្ចុប្បន្ននៅក្នុងទីក្រុង មិនអាចលាតសន្ធឹងរហូតដល់អាចចាត់ថាជាស្ថានភាពអាសន្នគំរាមកំហែងដល់សន្តិសុខជាតិនោះទេ។ បម្រាមមានវិសាលភាពទូលំទូលាយលើការជួបប្រជុំ ហើយមានការចាប់ខ្លួនជាបន្តបន្ទាប់នេះ ហាក់ដូចជាធ្វើឡើងដោយហេតុផលនយោបាយ ហើយប្រើសម្រាប់តែគោលបំណងការពាររដ្ឋាភិ–បាលបច្ចុប្បន្ន ដើម្បីកុំឲ្យមានការរិះគន់ពីសំណាក់កម្មកររោងចក្រ និងពីគណបក្សប្រឆាំងតែប៉ុណ្ណោះ ដូច្នេះនៅតែមានមន្ទិលសង្ស័យពីភាពស្របច្បាប់នៃបម្រាមនេះ។

លើសពីនេះទៅទៀត ក្នុងកថាខ័ណ្ឌទី២៥ នៃរបាយការណ៍របស់លោក ម៉ៃណា ទៅកាន់មហាសន្និបាតនៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៣ អ្នករាយការណ៍ពិសេសលោក ម៉ៃណា គីអៃ លើកឡើងពីសេរីភាពខាងការជួបប្រជុំក្នុងបរិបទនៃការបោះឆ្នោត បានគូសបញ្ជាក់ *"ដូចបានលើកឡើងពីខាងដើម បម្រាមទាំងស្រុង ដែលពុំមានលក្ខណៈសមហេតុផល និងមានលក្ខណៈរើសអើង គួរត្រូវបានហាមឃាត់ ហើយការរឹតត្បិតលើការជួបប្រជុំដោយសន្តិវិធីពាក់ព័ន្ធនឹង "ពេលវេលា ទីកន្លែង និងបែបបទ" គួរតែត្រូវបានកំណត់ ដើម្បីពង្រីកអត្ថន័យថា ការរឹតត្បិតនោះបំពេញតាមការពិសោធដ៏តឹងរ៉ឹងដូចបានរៀបរាប់ខាងលើជុំវិញពីភាពចាំបាច់ និងភាពសមហេតុផល"*។

<u>ការរឹតត្បិតលើសិទ្ធិជួបប្រជុំដោយសន្តិវិធីត្រូវតែមានចែងក្នុងច្បាប់</u>

មាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញចែងថា "*សិទ្ធិធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌច្បាប់*"។[15] ខណៈដែលមាត្រា ២១ នៃ ក.អ.ស.ព.ន ចែងថា "ការប្រើសិទ្ធិនេះ អាចមានការរឹតត្បិតដែលកំណត់ទៅតាមច្បាប់តែប៉ុណ្ណោះ"។[16]

នេះមានសារៈសំខាន់ក្នុងការសម្គាល់ថា គ្មានបទប្បញ្ញត្តិជាក់លាក់ណាក្នុងច្បាប់ជាតិកម្ពុជាបញ្ញត្តពីនីតិវិធីត្រូវអនុវត្តតាមនោះទេ ឬថាអាជ្ញាធរត្រូវអនុវត្តតាមបម្រាមនោះក៏ទេ។ មាត្រា ១២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិ–វិធីឆ្នាំ២០០៩ ចែងថា "*ក្រោយពីបានពិភាក្សាគ្នាហើយ បើភាគីទាំងពីរនៅតែមិនព្រមព្រៀងគ្នាទៀតនោះ អាជ្ញាធរដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចត្រូវស្នើសុំយោបល់សម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*"។[17] យ៉ាងណាក្តី បទប្បញ្ញត្តិនេះ ពាក់ព័ន្ធតែក្នុងករណីអ្នកដែលបញ្ជូនលិខិតជូនដំណឹងដើម្បីរៀបចំការជួបប្រជុំត្រូវបានអាជ្ញាធរមូលដ្ឋាន និងក្រសួងមហាផ្ទៃបដិសេធប៉ុណ្ណោះ ។ នេះមិនបានបញ្ញត្តពីការហាមប្រាមទូទៅ ប៉ុន្តែត្រូវអនុវត្តផ្អែកលើករណីម្តងមួយៗ។

បន្ថែមពីនេះ លោក សូរិយា ស៊ូប៊ែឌី អ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានផ្តល់អនុសាសន៍ក្នុងសេចក្តីថ្លែងការណ៍មួយចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ថា ៖

"*នោះគឺរដ្ឋាភិបាលត្រូវបញ្ជាក់បំភ្លឺដោយធ្វើលើមូលដ្ឋានច្បាប់ និងភាពត្រឹមត្រូវចំពោះបម្រាមបែបនេះ។ រដ្ឋាភិបាលត្រូវចងចាំថា នៅក្នុងមាត្រា ៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា រដ្ឋអាចចាត់វិធានការបដិប្បញ្ញត្តិ និងកាតព្វកិច្ចដែលមានចែងក្នុងកតិកាសញ្ញានេះ ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះ កុំឲ្យតែវិធានការទាំងនេះ មានវិសមិតភាពទៅនឹងវិធានការដទៃទៀត ចំពោះតែក្នុងស្ថានភាពអាសន្នជាសាធារណៈ ដែលបានគំរាមដល់អត្ថិភាពជាតិ និងភាពអាសន្នដែលត្រូវបានប្រកាសឡើងជាសាធារណៈ។ ខ្ញុំមិនបានឃើញពីការប្រកាសជាផ្លូវការនូវភាពអាសន្នជាសាធារណៈ ដែលគំរាមកំហែងដល់សន្តិសុខប្រទេសជាតិណាមួយនោះទេ។ កង្វះមូលដ្ឋានផ្លូវច្បាប់នេះ បម្រាមលើបាតុកម្មនោះគួរតែត្រូវបានដកចេញ*"[18]។

ជាចុងក្រោយ មាត្រា ២២ នៃរដ្ឋធម្មនុញ្ញ ចែងថា "*នៅពេលប្រជាជាតិប្រឈមនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា*"។[19] គ្មានស្ថានភាពអាសន្នត្រូវបានប្រកាសស្របតាមច្បាប់នៅ កម្ពុជានោះទេ។ បន្ថែមពីនេះ បម្រាមនោះត្រូវបានប្រកាស មិនមែនជាលិខិតស្នាមផ្លូវការ ប៉ុន្តែ ធ្វើឡើងតាមរយៈតែ សេចក្តីថ្លែងការណ៍របស់ក្រសួងមហាផ្ទៃ និងមិនមានចែងនៅក្នុងច្បាប់នោះទេ។

---

[15] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។ មាត្រា ៣៧ អាចរកបានតាម៖ http://bit.ly/19Ey1Ms។

[16] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) មាត្រា២១ អាចរកបានតាម៖ http://bit.ly/1eeGc40។

[17] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី មាត្រា១២ (ឆ្នាំ២០០៩) អាចរកបានតាម៖ http://bit.ly/1itCc0t> ។

[18] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស៖ សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្ត្រា សូរិយា ស៊ូប៊ែឌី (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤)អាចរកបានតាម៖ http://bit.ly/1rreypZ>។

[19] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា២២ អាចរកបានតាម៖http://bit.ly/19Ey1Ms>។

ដូចបានបង្ហាញមក ការហាមប្រាមទាំងស្រុងលើការជួបប្រជុំទាំងអស់ខ្វះភាពចាំបាច់ ខ្វះភាពសមហេតុផល និងភាពត្រឹមត្រូវ ព្រមទាំងមិនបានចែងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ដូច្នេះ ការហាមប្រាមនាពេលបច្ចុប្បន្ន របស់រដ្ឋាភិបាលទៅលើការជួបប្រជុំនេះ គឺពុំត្រឹមត្រូវតាមច្បាប់ និងជាការវាយប្រហារដោយផ្ទាល់ទៅលើសិទ្ធិសេរីភាព ខាងការជួបប្រជុំនៅកម្ពុជា។

## ការអនុវត្តន៍បម្រាមទៅលើការជួបប្រជុំ

កង្វះមូលដ្ឋានច្បាប់ចំពោះការហាមប្រាម និងកង្វះភាពប្រាកដប្រជាលើការអនុវត្តន៍បម្រាមនេះបានធ្វើអោយសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី ត្រូវបានអនុវត្តក្នុងលក្ខណៈធន្នានុសិទ្ធិទាំងស្រុង។ ម.ស.ម.ក បានរកឃើញថា សិទ្ធិសេរី–ភាពខាងការជួបប្រជុំបានត្រូវរដ្ឋាភិបាលកម្ពុជារឹតត្បិត ចាប់តាំងពីបម្រាមនេះត្រូវបានប្រកាសឡើងជាដំបូងនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤ រហូតដល់ពេលនេះ ដោយហាមប្រាមការតវ៉ា ការប្រើអំពើហិង្សាបង្ក្រាបក្រុមមនុស្ស ការបំភិតបំភ័យ និងតាមរយៈការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សជាបណ្តោះអាសន្ន ការតម្រូវឲ្យចុះហត្ថលេខាលើកិច្ចសន្យាដែលចែងថា ពួកគេនឹងបញ្ឈប់នូវសកម្មភាពនានារបស់ខ្លួននៅមុនពេលដោះលែង។ ការរឹតត្បិតលើសិទ្ធិជួបប្រជុំដោយសន្តិវិធី ត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយផ្សេងៗជាច្រើន។

<u>ការហាមឃាត់លើការតវ៉ាតាមតែអំពើចិត្ត</u>

ចាប់តាំងពីមានការហាមប្រាមលើការជួបប្រជុំ អាជ្ញាធរនៅក្នុងរាជធានីភ្នំពេញបានហាមឃាត់ការតវ៉ាមួយចំនួន និងអ្នកដទៃទៀតតាមតែអំពើចិត្ត មានន័យថា សិទ្ធិសេរីភាពខាងការជួបប្រជុំអាចធ្វើបានម្តងម្កាល ហើយលុះត្រាតែស្របតាមសុឆន្ទៈរបស់អាជ្ញាធរនោះទៀត។ ដូច្នេះ នេះច្បាស់ណាស់ថា បម្រាមលើការជួបប្រជុំគឺធ្វើឡើងតែដើម្បីឲ្យរដ្ឋាភិបាលបង្ក្រាបលើការតវ៉ានានាដែលបានគ្រោងឡើងដោយអ្នករិះគន់លើរដ្ឋាភិបាល។

ឧទាហរណ៍ បាតុកម្មមួយរបស់យុវជនគ្រោងនឹងធ្វើឡើងនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៤ បានសម្រេចធ្វើត្រឹមតែជាសន្និសិទ្ធសារព័ត៌មានទៅវិញ បន្ទាប់ពីរដ្ឋាភិបាលបានបដិសេធដកបម្រាមលើការជួបប្រជុំសាធារណៈរបស់ខ្លួន។ ការជួបប្រជុំរបស់យុវជនមានចំនួន៥០០នាក់នោះ មានបំណងដាក់ញត្តិអំពាវនាវឲ្យមានការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដែលនឹងអនុញ្ញាតឲ្យមានការបោះឆ្នោតជ្រើសរើសដោយផ្ទាល់លើសមាជិកក្រុមប្រឹក្សា ស្រុក ក្រុង និងខេត្ត។[20]

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ បន្ទាប់ពីសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលធ្វើឲ្យប្រជាពលរដ្ឋជឿថា បម្រាមនោះត្រូវបានដកហើយ តែអាជ្ញាធរបានប្រកាសថា ទីលានប្រជាធិបតេយ្យនៅតែមិនអោយធ្វើការតវ៉ាដោយគ្មានកំណត់ពេលវេលា ដែលនេះ ជាការបង្ហាញថែមទៀតថា បម្រាមលើការជួបប្រជុំជាសាធារណៈនោះ នៅមិន

---

[20] វង្ស សុខខេង៖ "យុវជនបានប្រាប់ថា បាតុកម្មនឹងមិនអនុញ្ញាតឲ្យធ្វើនៅតាមដងផ្លូវ" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1kNDVAw>។

ទាន់ត្រូវបានដកចេញនៅឡើយទេ។[21] រដ្ឋាភិបាលបានលើកហេតុផលម្ដងហើយម្ដងទៀតពីការព្រួយបារម្ភពីបញ្ហាសន្តិសុខ ចំពោះការបដិសេធរបស់ខ្លួនក្នុងការអនុញ្ញាតឲ្យមានបាតុកម្មនៅលើទីលានប្រជាធិបតេយ្យនោះ បើទោះជា រាល់ការតវ៉ា បានធ្វើឡើងនៅទីនោះបន្ទាប់ពីការបោះឆ្នោតដ៏ចម្រូងចម្រាសកាលពីខែកក្កដា ប្រកបដោយសន្តិវិធីក៏ដោយ។ សាលាក្រុងភ្នំពេញបានច្រានចោលសំណើសុំធ្វើការជួបប្រជុំនៅលើទីលានប្រជាធិបតេយ្យជាច្រើនលើកច្រើនសារ របស់សហជីព និងសមាគម ក៏ដូចជា សំណើរបស់ម្ចាស់ស្ថានីយវិទ្យុសំបុកឃ្មុំលោក ម៉ម សូណង់ដូ ជាដើម។[22]

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ សាលាក្រុងបានបដិសេធជាថ្មីម្ដងទៀតនូវការតវ៉ាគ្រោងរៀបចំឡើងរបស់លោក ម៉ម សូណង់ដូ ដោយលើកហេតុផលថា ជាការចាំបាច់ដើម្បីស្ដារនូវសណ្ដាប់ធ្នាប់សាធារណៈ។ លោក ម៉ម សូណង់ដូ បានសុំការអនុញ្ញាតម្ដងហើយម្ដងទៀត ដើម្បីតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ក្រសួងព័ត៌មានចំពោះការបដិសេធក្នុងការផ្ដល់អាជ្ញាប័ណ្ណទូរទស្សន៍ និងពង្រីកប្រេកង់វិទ្យុ ដោយលោកអភិបាលរងក្រុងភ្នំពេញ លោក ឃួង ស្រេង បានជូនដំណឹងថា បាតុកម្មនោះគួរតែត្រូវពន្យាពេល។ យ៉ាងណាក្ដី លោក សូណង់ដូ មិនត្រូវបានសាលាក្រុង ផ្ដល់កាលបរិច្ឆេទផ្សេងទៀតទេនៅពេលស្នើសុំនោះ។ អ្នកនាំពាក្យសាលាក្រុងភ្នំពេញ លោក ឡុង ឌីម៉ង់ បានប្រកាសថា បាតុកម្មមិនអាចប្រព្រឹត្តទៅបានទេ រហូតដល់ "*ស្ថានភាព និងសណ្ដាប់ធ្នាប់សាធារណៈបានត្រឡប់ទៅរកស្ថានភាពធម្មតាវិញ*" ហើយរហូតដល់ការស៊ើបអង្កេតក្នុងករណីសម្លាប់លើកម្មកររោងចក្រដែលបានធ្វើឡើងនៅដើមខែ មករា បានចប់សព្វគ្រប់។[23]

ខណៈដែលបម្រាមនោះនៅតែមាន បរិយាកាសនៃសេរីភាពខាងការជួបប្រជុំនៅតែខុសច្បាប់។ តាមការអនុវត្តន៍ជាក់ស្ដែង បម្រាមលើការជួបប្រជុំ បានព្យួរការអនុវត្តច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩។ បម្រាមនៅក្នុងខេត្តកំពង់ឆ្នាំងនោះ ពិតជាបង្ហាញថា សិទ្ធិជួបប្រជុំនាពេលបច្ចុប្បន្ននេះត្រូវបានបដិសេធ ឬត្រូវបានអនុញ្ញាតអាស្រ័យលើការសម្រេចរបស់ស្ថាប័ននីតិប្រតិបត្តិ ជាជាងការអនុវត្តតាមច្បាប់។

<u>ការបំភិតបំភ័យ និងការប្រើអំពើហិង្សា</u>

ការហាមឃាត់ការតវ៉ា ដោយផ្អែកលើការហាមប្រាមការជួបប្រជុំនៅពេលបច្ចុប្បន្ននេះ ប្រគល់អំណាចឲ្យរដ្ឋាភិបាលបង្ក្រាបដោយហិង្សាលើអ្នកតវ៉ា។ ជាក់ស្ដែង នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៤ អាជ្ញាធរបានរាំងវេទិកាសាធារណៈមួយដែលគ្រោងរៀបចំឡើងស្ដីពីបញ្ហាជុំវិញវិស័យកាត់ដេរ នៅទិវាសិទ្ធិនារីអន្តរជាតិ។ នៅវេលាម៉ោង ៧ព្រឹក នគរបាល

---

[21] ម៉ុម គុន្ធា "មានការកំណត់ចំនួនអ្នកតវ៉ានៅទីលានប្រជាធិបតេយ្យ៖ សាលាក្រុង កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1cEkgk2>។

[22] គុច ណារ៉ែន និង មិច ដារា "ភាពមិនច្បាស់លាស់លើការហាមប្រាមលើការធ្វើបាតុកម្ម" កាសែត *ខេមបូឌា ដេលី* (ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/OPGJjl>។

[23] គុច ណារ៉ែន "សាលាក្រុងច្រានចោល គម្រោងតវ៉ារបស់លោក ម៉ម សូណង់ដូ" កាសែត *ខេមបូឌា ដេលី* (ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1gww7ln> ។

បានបិទច្រកចូលសួន និងបិទផ្លូវធ្វើដំណើរចូលទៅកាន់ទីនោះ ទើប១ម៉ោងក្រោយមក កងសន្តិសុខខ័ណ្ឌដូនពេញពាក់មួកការពារសុវត្ថិភាពពណ៌ខ្មៅបានមកបំបែកដោយបង្ខំលើក្រុមមនុស្សដែលបានមកប្រមូលផ្តុំគ្នានៅជិតច្រកបិទនោះ។[24]

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ការជួបប្រជុំដោយសន្តិវិធីនៅក្រៅក្រសួងព័ត៌មាន ដែលដឹកនាំដោយលោក ម៉ម សូណង់ដូ ត្រូវបានបង្ក្រាបយ៉ាងហិង្សានៅវេលាម៉ោងប្រមាណ១០ព្រឹក។ កងរាជអាវុធហត្ថរាប់រយនាក់បានវាយសម្រុកទៅលើក្រុមមនុស្ស ដោយប្រើដំបង គ្រាប់បែកផ្សែងដើម្បីបង្ក្រាបលើការជួបប្រជុំនោះ។ កងសន្តិសុខខ័ណ្ឌពាក់មួកការពារសុវត្ថិភាព ក៏បានចូលរួមបង្ក្រាបទៅលើការជួបប្រជុំនោះដែរ ដោយប្រើដំបងវាយទៅលើ អ្នកចូលរួម និងអ្នកសារព័ត៌មានដែលមានវត្តមាននៅទីនោះ។ ការប្រើអំពើហិង្សានោះបានធ្វើឲ្យមនុស្សជាង១០នាក់រងរបួស។[25]

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤ កងកម្លាំងសន្តិសុខបានវាយដំដោយដំបងទៅលើអ្នកតវ៉ាដែលព្យាយាមជួបជុំគ្នានៅលើទីលានប្រជាធិបតេយ្យ ហើយបានបុកអ្នកតវ៉ាដោយជន្លួញអេឡិចត្រូនិច។ អ្នកតវ៉ាម្នាក់បានទាត់សន្តិសុខដែលពាក់មួកសុវត្ថិភាពម្នាក់ចំក្រលៀននៅជិតស្ពាននាគរហូតដល់មានអំពើហិង្សា។ សហជីព និងសមាគមចំនួន៩ បានប្រមូលផ្តុំគ្នា ដើម្បីទាមទារឲ្យធ្វើការដោះលែងមនុស្សទាំង២៣នាក់ដែលជាប់ឃុំនៅដើមខែមករា និងទាមទារឲ្យមានការតម្លើងប្រាក់ឈ្នួលអប្បបរមាចំនួន១៦០ ដុល្លាដល់កម្មករកម្ពុជាទាំងអស់។ នៅមុនបាតុកម្មនោះ១សប្តាហ៍ រដ្ឋាភិបាលបានច្រានចោលនូវសំណើសុំធ្វើបាតុកម្មរបស់ពួកគេ។[26]

ការបំភិតបំភ័យនៃអំពើហិង្សាបានត្រូវគេប្រើផងដែរ ដើម្បីរារាំង ការជួបប្រជុំ។ ឧទាហរណ៍កិច្ចប្រជុំមួយរបស់ គ.ស.ជ នៅឃុំត្រើយស្លា ខេត្តកណ្តាល ត្រូវបានលុបចោលវិញកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ បន្ទាប់ពីអ្នកគាំទ្ររបស់គណបក្សប្រជាជន ("ប្រ.ជ") ជាច្រើនរយនាក់ហើយនិងនគរបាលប្រឆាំងកុប្បកម្ម និងកងរាជអាវុធហត្ថប្រដាប់ដោយកាំភ្លើងគ្រាប់ផ្សែង របាំងការពារ និងដំបងមានវត្តមាននៅកន្លែងជួបប្រជុំនោះ។ កិច្ចប្រជុំនោះត្រូវបានផ្អាកវិញ នៅមុនបន្តិចនៃដំណើរមកដល់របស់ថ្នាក់ដឹកនាំ គ.ស.ជ ក្នុងគោលបំណងដើម្បីបញ្ចៀសអំពើហិង្សា ដោយសារតែមានវត្តមានរបស់កម្លាំងសន្តិសុខច្រើនពេក។[27] គ.ស.ជ បានទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង ឲ្យមានការជួបប្រជុំ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ ប៉ុន្តែ តាមជាក់ស្តែង ការបង្ហាញពីពីចំនួនកងកម្លាំងសន្តិសុខដ៏ច្រើន និងអ្នកគាំទ្ររបស់ ប្រ.ជ គឺជាសាររារាំងដ៏ច្បាស់មួយ ក្នុងគោលបំណងរឹតត្បិតលើសិទ្ធិជួបប្រជុំដោយសន្តិវិធីរបស់គណ

---

[24] មិច ដារា " បម្រាមលើការតវ៉ានៅថ្ងៃទិវាសិទ្ធិនារី" កាសែត *ខេមបូឌា ដេលី* (ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/1gf8N9Y។

[25] យុត សុភ័ក្រ ចរិយា និងខេរិន ប៉ូណា "ការប្រមូលផ្តុំត្រូវបានបំបែកដោយហិង្សា" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៨ ខែ មករា ឆ្នាំ២០១៤) អាចរកបានតាម៖<http://bit.ly/1iF64Jy>។

[26] ស៊ាន ទីហាន និងដាញ៉ែល ឃ្វីនលែន "មានអំពើហិង្សាកាន់តែច្រើននៅទីលានប្រជាធិបតេយ្យ" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖< http://bit.ly/1kflssi>។

[27] ផាន់ អាណា និង អុន ភាព "គ.ស.ជ លុបចោលកិច្ចប្រជុំ ខណៈដែលអ្នកគាំទ្ររបស់ ប្រ.ជ ចេញមកជាកងកម្លាំង" កាសែត ខេមបូឌា ដេលី (ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖<http://bit.ly/1m3dvc7>។

បក្សប្រឆាំង។ ឧបាយកលគំរាមកំហែងស្រដៀងគ្នានេះ ត្រូវបានប្រើដើម្បីរារាំងដល់ការជួបប្រជុំជាមួយលោក កឹម សុខា អនុប្រធាន គ.ស.ជ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤ ក្នុងខេត្តកំពង់ចាម។[28]

បន្ថែមពីនេះ អ្វីដែលជាការព្រួយបារម្ភដ៏ធំនោះគឺ សាលាក្រុងភ្នំពេញបានជួលកងកម្លាំងសន្តិសុខឯកជនជាលក្ខណៈប្រព័ន្ធ ដែលពុំបានហ្វឹកហ្វឺនត្រឹមត្រូវដើម្បីបំបែកបាតុកម្មដោយបង្ខំនិងចាប់ខ្លួនអ្នកតវ៉ានៅក្នុងរាជធានីភ្នំពេញ។ យោងតាមលោក ឡុង ឌីម៉ង់ អ្នកនាំពាក្យសាលាក្រុងភ្នំពេញ កងកម្លាំងសន្តិសុខស្លៀកឯកសណ្ឋានស៊ីវិលទាំងនោះមិនទទួលបានការបណ្តុះបណ្តាលស្តីពីសន្តិសុខត្រឹមត្រូវទេ តែពួកគេបានទទួលវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ និងផ្នែករដ្ឋបាល។ លោក ឌីម៉ង់ បានបដិសេធបកស្រាយលម្អិតពី វគ្គបណ្តុះបណ្តាលដែលបានទទួល ពីទំហំនៃការប្រើកងកម្លាំងតាមការបញ្ជារបស់សាលាក្រុងភ្នំពេញ ឬពីពេលវេលាចេញបទបញ្ជានោះ។ ជារឿយៗ កងកម្លាំងដែលពុំទទួលបានការបណ្តុះបណ្តាលទាំងនោះ តែងប្រដាប់ដោយដំបង និងរបាំងដែកដើម្បីបង្ក្រាបដោយបង្ខំទៅលើអ្នកតវ៉ា។ តាមធម្មតា កងសន្តិសុខទាំងនោះអាចសម្គាល់បានតាមរយៈការស្លៀកពាក់ឯកសណ្ឋានមិនប្រាកដប្រជា និងពាក់មួកការពារសុវត្ថិភាពព័ណ៌ខ្មៅ តែទោះយ៉ាងណា កងកម្លាំងសន្តិសុខមួយចំនួន ស្លៀកពាក់ឯកសណ្ឋានខ័ណ្ឌដូនពេញ ដែលបានរាយការណ៍ថាពួកគេពុំទទួលបានការបណ្តុះបណ្តាលស្តីពីសន្តិសុខសម្រាប់ការងារ និងមិនដឹងប្រាកដថាតើពួកគេទទួលបានប្រាក់ខែមកពីណានោះទេ។[29] កង្វះការបណ្តុះបណ្តាលដល់សន្តិសុខ លើកជាក្តីបារម្ភធ្ងន់ធ្ងរ ខណៈដែលអ្នកទាំងនោះពុំមានចំណេះដឹងពីរបៀបគ្រប់គ្រងក្រុមមនុស្សឲ្យបានត្រឹមត្រូវ។ ម្យ៉ាងទៀត ដោយសារកម្លាំងសន្តិសុខពុំមានការបណ្តុះបណ្តាល ត្រូវបានជួលជាលក្ខណៈឯកជន នៅពេលដែលកងកម្លាំងនេះ ប្រើអំពើហិង្សា ដែលជាករណីកើតឡើងញឹកញាប់ ពេលនោះ គេមិនអាចវែករកមុខអ្នកទទួលខុសត្រូវនោះទេ ដែលប្រការនេះ កាន់តែបង្កើនឲ្យមានវប្បធម៌និទណ្ឌភាព។

## ការចាប់ខ្លួនជាបណ្តោះអាសន្នទៅលើអ្នកតវ៉ា

នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ សកម្មជនដីធ្លីចំនួន៥នាក់មកពីសហគមន៍បឹងកក់ ត្រូវបានចាប់ខ្លួនជាបណ្តោះអាសន្នក្នុងរាជធានីភ្នំពេញ។ នៅម៉ោង ៨:០០នាទីព្រឹក អ្នកស្រី ទេព វន្នី អ្នកស្រី យ៉ោម បុប្ផា បូ ឆវី ផាន់ ឈុនរ៉េត និងសុង ស្រីលាភ បានហែក្បួនទៅកាន់ស្ថានទូតបារាំងដើម្បីស្នើឲ្យដោះលែងលោក វន់ ពៅ និងបាតុករអហិង្សាចំនួន៩នាក់ផ្សេងទៀត ដែលត្រូវបានអាជ្ញាធរចាប់ខ្លួនកាលពីថ្ងៃទី០២ ខែមករា។ សកម្មជនចំនួន៥នាក់ត្រូវនគរបាលចាប់ខ្លួន នៅម៉ោងប្រហែល៨:៤០នាទីព្រឹក ហើយភ្លាមនោះ ពួកគេត្រូវបានបញ្ជូនទៅកាន់ស្នងការនគរបាលរាជធានី

---

[28] ម៉ៃ ទិត្យថារ៉ា និងស្តាដវ៉ាយ "គ្មានការពិភាក្សានៅពាក់កណ្តាលអំពើហិង្សា៖ សុខា កាសែត ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖ <http://bit.ly/1mrsK1n>។

[29] ឃួត សុភ័ក្រ ចរិយា និងហ្សែន វ៉ែល " កងសន្តិសុខដែលពុំមានការបណ្តុះបណ្តាលត្រឹមត្រូវគ្រប់គ្រងលើអ្នកតវ៉ា" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1fcN6Ut។

ភ្នំពេញ។ សកម្មជនទាំង៥នាក់នេះ ត្រូវបានដោះលែងមកវិញនៅម៉ោង ៤:៤៥នាទីល្ងាច បន្ទាប់ពីពួកគេបានព្រមព្រៀងចុះហត្ថលេខាលើលិខិតមួយច្បាប់ ដោយបានសន្យាថា ពួកគេនឹងមិនចូលរួមបណ្តោះអាសន្នក្នុងការតវ៉ា។[30]

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤ លោក សុខ ឈុនអឿង ប្រធានស្តីទីសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ(“អាយឌា”) ត្រូវបានចាប់ខ្លួនខណៈលោកប៉ុនប៉ងរៀបចំការតវ៉ាដោយស្ងៀមស្ងាត់មួយដើម្បីឲ្យមានការដោះលែងអ្នកទាំង២៣នាក់ ដែលត្រូវបានអាជ្ញាធរឃុំខ្លួនចាប់តាំងពីការប៉ះទង្គិចដោយហិង្សានៅថ្ងៃទី០២ ទី០៣ ខែមករា ឆ្នាំ២០១៤។ លោកត្រូវបានឃុំខ្លួនពេញមួយយប់នៅស្នងការនគរបាលរាជធានីភ្នំពេញ ហើយបានត្រូវដោះលែងវិញបន្ទាប់ពីចុះហត្ថលេខាលើលិខិតស្រដៀងគ្នាមួយ។[31]

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ សកម្មជនសិទ្ធិមនុស្សចំនួន១១នាក់ និងអ្នកតវ៉ាអហិង្សាជាច្រើននាក់ត្រូវបានកងកម្លាំងសន្តិសុខខ័ណ្ឌដូនពេញចាប់ខ្លួនជាបណ្តោះអាសន្ន ហើយត្រូវបានបញ្ជូនទៅស្នងការនរគបាលរាជធានីភ្នំពេញ។ អ្នកទាំង១១នាក់ដែលត្រូវចាប់ខ្លួននោះគឺ សកម្មជនបឹងកក់អ្នកស្រី ទេព វន្នី អ្នកស្រីយ៉ោម បុប្ផា សុង ស្រីលាភ ផាន់ ឈុនរ៉េត គួង សុភាព អ៊ឹម ស្រីតូច បៅ សោភា ងួន គឹមឡាង និង លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យ ជាង ធីតា បុគ្គលិកសម្ព័ន្ធសហជីពកម្ពុជា និង កញ្ញា ឡុង គឹមហៀង សមាជិកនៃក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន។ ការចាប់ខ្លួនអ្នក៦នាក់ដំបូង បានកើតឡើងនៅពីមុខស្ថានទូតសហរដ្ឋអាមេរិក ក្នុងអំឡុងពេលបាតុកម្មមួយដើម្បីដាក់ញត្តិអំពាវនាវឲ្យមានការដោះលែងសកម្មជន និងកូដករទាំង២៣នាក់ ដែលត្រូវបានតុលាការដាក់ពន្ធនាគារនៅដើមខែមករា។ រីឯមនុស្ស៥នាក់ផ្សេងទៀត ត្រូវបានចាប់ខ្លួនប្រហែលជា១០នាទីក្រោយមក ខណៈពួកគេធ្វើដំណើរទៅកាន់ស្ថានទូតបារាំង។ មនុស្សទាំង១១នាក់ត្រូវបានដោះលែងនៅរសៀលថ្ងៃនោះបន្ទាប់ពីបានចុះហត្ថលេខាលើលិខិតមួយច្បាប់ដែលចែងថាពួកគេនឹងមិនញុះញង់ ឬចូលរួមក្នុងសកម្មភាព ឬបាតុកម្មខុសច្បាប់នានាទៀតឡើយ។[32]

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៤ យុវជន៧នាក់ (ស្ត្រីពីរនាក់ និងប្រុស៥នាក់) ត្រូវបានអាជ្ញាធរឃុំខ្លួនបណ្តោះអាសន្នក្នុងរាជធានីភ្នំពេញ ខណៈដែលពួកគេហែក្បួនអំពាវនាវឲ្យមានសន្តិភាព។ យុវជនទាំងនោះ គឺជាសមាជិករបស់អង្គការមួយឈ្មោះថា ក្លឹបយុវជនខ្មែរមហានគរ ដែលលើកស្ទួយយុវជន និងគាំទ្រយុត្តិធម៌សង្គម។ យុវជនទាំងនោះត្រូវបានដោះលែងវិញនៅថ្ងៃដដែល បន្ទាប់ពីបានចុះហត្ថលេខាលើលិខិតសន្យាមិនហែក្បួនដោយពុំមានការអនុញ្ញាត។[33]

---

30 ម.ស.ម.ក ការដោះលែងដោយមានលក្ខខណ្ឌលើអ្នកការពារសិទ្ធិមនុស្ស រំលោភលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងជួបប្រជុំជាមូលដ្ឋាន (កំណត់ត្រាសង្ខេប) (ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1g4udIw>។

31 ខួត សុភ័ក្រ ចរិយា និងស៊ាន ទីហាន “មេដឹកនាំសហជីពត្រូវបានដោះលែងវិញ” កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖<http://bit.ly/1joXtfi>។

32 ភ័ណ បុប្ផា និង ខូលីន មីយ៉ាន “ចាប់ខ្លួនសកម្មជនទាំង១១នាក់ ព្រោះថាធ្វើឲ្យ “ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ” កាសែត *ខេមបូឌាដេលី* (ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖ <http://bit.ly/NMvpnl>។

33 ហ៊ុល រស្មី និងម៉េច ដារ៉ា “ព្រឹត្តិការណ៍លើកកម្ពស់សន្តិភាព ត្រូវបានបញ្ឈប់ដោយអាជ្ញាធរ” កាសែត *ខេមបេឌា ដេលី* (ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/OPGJjl>។

នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ អតីតប្រជាពលរដ្ឋសហគមន៍បឹងកក់ចំនួនបីនាក់ ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន បន្ទាប់ពីពួកគាត់បានចតម៉ូតូកង់បី ដោយបំពងសំឡេងឃោសនសព្ទនៅខាងក្រៅសាលាក្រុង ដើម្បីអំពាវនាវដល់លោកអភិបាលក្រុង ប៉ា សុជាតិវង្ស ផ្ដល់សំណងបន្ថែមសម្រាប់ការបាត់បង់ផ្ទះសម្បែងដោយការបណ្ដេញចេញដោយបង្ខំ។ កងកម្លាំងសន្តិសុខស្លៀកពាក់ឯកសណ្ឋានស៊ីវិលរបស់ខ័ណ្ឌដូនពេញ បានឃុំខ្លួនពួកគេនៅទីស្នាក់ការកណ្ដាលនគរបាលក្រុង អស់រយៈពេលពីរបីម៉ោង។[34]

ការឃុំខ្លួនបណ្ដោះអាសន្នលើអ្នកការពារសិទ្ធិមនុស្ស និងការតវ៉ាដោយសន្តិវិធី ព្រមទាំងការតម្រូវឲ្យចុះហត្ថលេខាលើលិខិតដោយសន្យាថាពួកគេនឹងបញ្ឈប់នូវសកម្មភាពនានារបស់ខ្លួននោះ គឺជាការប៉ុនប៉ងរឹតត្បិតដ៏ច្បាស់លើបរិយាកាសបំពេញការងាររបស់អ្នកការពារសិទ្ធិមនុស្ស និងជាការប៉ុនប៉ងបញ្ឈប់នូវសកម្មភាពនានារបស់ពួកគេដោយពិតប្រាកដ។

## សេចក្ដីសន្និដ្ឋានបញ្ចប់ និងអនុសាសន៍

ការហាមប្រាមទាំងស្រុងនាពេលបច្ចុប្បន្ននេះ លើការជួបប្រជុំ ការធ្វើបាតុកម្ម និងការហែក្បួនបានប្រកាសដោយក្រសួងមហាផ្ទៃគ្មានមូលដ្ឋានច្បាប់ ហើយរំលោភលើកាតព្វកិច្ចរបស់រដ្ឋាភិបាលក្រោមច្បាប់ជាតិ និងច្បាប់អន្ត–រជាតិ ខណៈដែលបម្រាមនេះ មានវិសាលភាពទូលំទូលាយជ្រុលពេក គ្មានលក្ខណៈសមហេតុផលទាល់តែសោះ ហើយមិនស្របតាមគោលបំណងច្បាប់។ បម្រាមបច្ចុប្បន្ននេះ នៅតែកំពុងអនុវត្ត បើទោះជាមានសុន្ទរកថាឲ្យដកបម្រាមនោះរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅតាមបណ្ដាញផ្សព្វផ្សាយព័ត៌មានផ្សេងៗនោះក្ដី។ ការយល់ច្រឡំជុំវិញស្ថានភាពបច្ចុប្បន្នពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃបម្រាមនេះ ឬក៏បម្រាមនេះនៅតែមានអានុភាព នាំអោយ រដ្ឋាភិបាលអាចហាមឃាត់ បង្ក្រាប និងចាប់ខ្លួនលើអ្នកតវ៉ានានាតាមតែអំពើចិត្ត។ នេះប្រាកដណាស់ថា បម្រាមលើការជួបប្រជុំដ៏មានវិសាលភាពទូលំទូលាយនេះ គឺជាប់ពាក់ព័ន្ធដោយហេតុផលនយោបាយ ហើយប្រើសម្រាប់តែគោលបំណងការពាររដ្ឋាភិបាលបច្ចុប្បន្ន ដើម្បីកុំឲ្យមានការរិះគន់ពីសំណាក់កម្មកររោងចក្រ និងពីគណបក្សប្រឆាំងតែប៉ុណ្ណោះ។ បម្រាមលើការជួបប្រជុំ និងឧបាយកលរឹតត្បិតនានាដូចបានពិព័ណ៌នាខាងលើ គឺជាការវាយប្រហារដោយផ្ទាល់ទៅលើសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីនៅកម្ពុជា។ ដូច្នេះហើយ ម.ស.ម.ក សូមផ្ដល់អនុសាសន៍ឲ្យ រដ្ឋាភិបាលគួរៈ

- និរាករណ៍ជាបន្ទាន់ និងជាផ្លូវការនូវបម្រាមលើការជួបប្រជុំគ្រប់យ៉ាង ការហែក្បួន និងការធ្វើបាតុកម្មនានានៅកម្ពុជា ។
- បញ្ឈប់ការឃុំខ្លួនបណ្ដោះអាសន្នដោយខុសច្បាប់លើអ្នកតវ៉ាដោយសន្តិវិធី និងដោះលែងអ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ឃុំ ដោយសារចូលរួមនៅក្នុងសកម្មភាពតវ៉ាដោយសន្តិវិធី។

[34] គួច ណារ៉ែន និង ម៉េច ដារ៉ា "ភាពមិនច្បាស់លាស់លើការហាមប្រាមលើបាតុកម្ម" កាសែត ខេមបូឌា ដេលី (ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤) អាចរកបានតាម៖<http://bit.ly/OPGJjl>។

- បញ្ឈប់ការអនុវត្តន៍ការបង្ខិតបង្ខំចំពោះអ្នកការពារសិទ្ធិមនុស្ស និងពលរដ្ឋដែលគ្រាន់តែអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការជួបប្រជុំជាមូលដ្ឋានរបស់ខ្លួនឲ្យចុះហត្ថលេខាលើកិច្ចសន្យាមានលក្ខណៈរឹតត្បិតលើសិទ្ធិរបស់ពួកគាត់ ដើម្បីជាថ្នូរនឹងការដោះលែង ឬរួចផុតពីការចោទប្រកាន់នានា។
- លុបចោលនូវលិខិតដែលបានប្រកាសរួច ហើយត្រូវចាត់ទុកលិខិតទាំងនោះជាមោឃៈ។
- បញ្ឈប់ការឃោឃីផ្នែកនយោបាយ និងការធ្វើទុក្ខបុកម្នេញផ្នែកតុលាការ ហើយនិងអំពើហិង្សាលើអ្នកតវ៉ាដោយសន្តិវិធី និងលើអ្នកការពារសិទ្ធិមនុស្ស។
- ធានាឲ្យមន្ត្រីសន្តិសុខទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ហើយបញ្ឈប់ការជួលកងកម្លាំងសន្តិសុខឯកជននិង,
- ធានាថា ការរឹតត្បិតលើសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីនោះ ត្រូវបានហាមប្រាមនៅពេលអនាគត។
- ធានាថា សិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី ត្រូវបានគោរព និងអនុវត្តតាមយ៉ាងពេញលេញ និងធានាថា ច្បាប់ធរមាននានា ត្រូវបានអនុវត្ត និងគោរពយ៉ាងត្រឹមត្រូវ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង កញ្ញា សន រ៉ាម៉ាណា អ្នកសម្របសម្រួលគម្រោងសេរីភាពបញ្ចេញមតិ តាមរយៈទូរសព្ទ ៖ (០) ៧៧ ៤០ ៥៣ ៦៣ ឬអ៊ីម៉ែល ៖ramanasorn@cchrcambodia.org ឬលោកស្រី អេលីស ជីលែត តាមរយៈទូរសព្ទ៖(០) ៧៧ ៧០ ៩៧ ២៣ ឬអ៊ីម៉ែល ៖elise.tillet@cchrcambodia.org។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA